...ថ្ងៃទី...០៥...ខែ ០៤
...ឆ្នាំ...ម៉ោង...
...លេខចុះ...០០៤...

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ:០១ ប្រ.ក.

## សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល
## ស្តីពី ការកែទំរង់រដ្ឋបាលសាធារណៈ

គោលដៅដ៏ធំបងរបស់រាជរដ្ឋាភិបាល គឺធានាសុខមាលភាពសង្គមនិងសេដ្ឋកិច្ចរបស់ប្រជារាស្ត្រកម្ពុជា ពោលគឺការស្តែងចេញនូវការប្តេជ្ញាចិត្តយ៉ាងមុះមុតរបស់រាជរដ្ឋាភិបាលដើម្បីធ្វើអោយសង្វាក់នៃការលូតលាស់សេដ្ឋកិច្ចយូរអង្វែង ដោយផ្អែកលើមូលដ្ឋាននៃបញ្ញត្តិសេដ្ឋកិច្ចទីផ្សារកាន់តែលឿនឡើងហើយ និងស្ថាបនាឡើងវិញនូវសមធម៌ យុត្តិធម៌សង្គម និងសន្តិភាព ដោយឈរលើស្មារតីផ្សះផ្សាជាតិ ។ គោលដៅខាងលើនេះ និង អនុញ្ញាតអោយការប្រើប្រាស់ធនធានក្នុងប្រទេស ទទួលបានទិន្នផលកើតខ្ពស់ប្រសើរបំផុត និង បើកលទ្ធភាពជូនប្រជារាស្ត្រទទួលផល នៃការលូតលាស់នេះ ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តកម្មវិធីជាតិសំរាប់និតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាមួយដ៏ទូលាយ និងប្រកបដោយមហិច្ឆតាសំរាប់បណ្តាឆ្នាំខាងមុខ ។ ក្នុងវិធានការដែលរាជរដ្ឋាភិបាលប្រកាន់យកលើវិស័យហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ច ជាពិសេសផ្នែក កសិកម្ម ឧស្សាហកម្ម សុខាភិបាល អប់រំ ... មានកម្មវិធីជាតិ « កំណែទំរង់រដ្ឋបាលសាធារណៈ » ដែលដើរតួសំខាន់ហើយដែលជាកត្តាកំណត់ក្នុងការសំរេចជោគជ័យនយោបាយរបស់រាជរដ្ឋាភិបាល ។

គោលដៅធំធេង នៃកំណែទំរង់នេះ គឺផ្តល់ដល់ជាតិនូវ « សេវាសាធារណៈ » មួយដែលឯកភាព ស្អាតស្អំ អព្យាក្រឹត និងមានសមត្ថភាពអាច ÷

- បំរើប្រជារាស្ត្រខេត្ត - ក្រុង ដោយប្រសិទ្ធភាព
- ពង្រឹងស្ថេរភាព សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយក្នុងការអភិវឌ្ឍប្រទេសជាតិ។

ដើម្បីសំរេចគោលដៅនេះ ចាំបាច់ត្រូវតែ ÷

១- រៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋ

២- ពង្រឹងសមត្ថភាពគ្រប់គ្រង នៃ ក្រសួងប្រតិបត្តិនានា

៣- កែទំរង់មុខងារសាធារណៈ

៤- អភិវឌ្ឍធនធានមនុស្ស

៥– ពង្រឹងសមត្ថភាពគ្រប់គ្រងរដ្ឋបាលខេត្ត–ក្រុង ។

កន្លងមកនេះ ក្របខ័ណ្ឌគតិយុត្តិ និង លិខិតបទដ្ឋាននានាត្រូវបានដាក់អោយប្រើប្រាស់ ក្នុងនោះរចនាសម្ព័ន្ធ និងអង្គការនានាត្រូវបានបង្កើតឡើង ដើម្បីដាក់អោយដំណើរការនូវនយោបាយកែទំរង់នេះ ។ វិធានការបន្ទាន់សំខាន់ៗដែលរាជរដ្ឋាភិបាលបានប្រកាន់យក ដើម្បីប្រឈមមុខទៅនឹងអសុក្រឹតកម្ម នៃរដ្ឋបាលសាធារណៈមានដូចតទៅ ÷

ក– ការជ្រើសរើសមន្ត្រីរាជការ និងប្រព្រឹត្តទៅដោយវិធីប្រឡងប្រជែង និងទៅតាមសេចក្តីត្រូវការពិតប្រាកដ នៃរដ្ឋបាល គឺមិនមែនធ្វើឡើងដោយសមាហរណកម្មស្វ័យប្រវត្តិទៀតឡើយ

ខ– ការបញ្ចប់សមាហរណកម្មទៅក្នុងរដ្ឋបាល នូវមន្ត្រីរាជការ ពីគ្រប់ភាគីហត្ថលេខីខ្មែរ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស

គ– ការលុបបំបាត់អនិយតភាពដែលមាននៅក្នុងការគ្រប់គ្រងរដ្ឋបាលបច្ចុប្បន្ន

ឃ– ការកាត់បន្ថយមន្ត្រីរាជការស៊ីវិលចំនួន ២០% ចាប់ពីពេលនេះរហូតដល់ឆ្នាំ ១៩៩៧

ង– ការកំណត់យន្តការនៃសមាហរណកម្មសង្គមដើម្បីបញ្ចូលមន្ត្រីរាជការទៅក្នុងផ្នែកឯកជន។

បើគ្មានវិធានការនេះទេ បណ្តាស្ថាប័នរដ្ឋក្នុងរាជធានី ក៏ដូចជាក្នុងខេត្ត–ក្រុង នៅតែបន្តទ្រទ្រង់បន្ទុកដ៏ធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ ដែលបង្កើននូវភាពលំបាកដល់ថវិការដ្ឋមួយផ្នែក និងមួយផ្នែកទៀតភាពសមស្របរវាងចំនួនមន្ត្រីរាជការ នឹងទំហំពិតប្រាកដ នៃការងារ មិនអាចរៀបចំបានឡើយ ។

ដើម្បីលើកតំលៃ និងកែលំអឡើងនូវការគ្រប់គ្រង នៃមន្ត្រីរាជការរាជរដ្ឋាភិបាលបានសំរេចយកអាទិភាពទីមួយគឺ បើកប្រតិបត្តិការរាប់ចំនួនមន្ត្រីរាជការ ចាប់ពីថ្ងៃទី ០៧ កុម្ភៈ ឆ្នាំ ១៩៩៥ តទៅ ។ បន្ទាប់ពីប្រតិបត្តិការនេះ នឹងមានការជំរឿនដ៏ពេញលេញទូទាំងប្រទេសដើម្បី ÷

១– លុបបំបាត់អនិយតភាពដែលមានសព្វថ្ងៃ ជាពិសេស ÷

១–១– ចំនួនមន្ត្រីរាជការក្នុងបញ្ជីបើកប្រាក់បៀវត្សមានលើសពីចំនួនពិតប្រាកដ

១–២– មនុស្សតែម្នាក់ធ្វើការក្នុងស្ថាប័នច្រើនកន្លែង

១–៣– ការមិនគោរពតាមនីតិក្រម នៃការចូលនិវត្ត

១–៤– ការយកអត្រានុកូលដ្ឋានរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន

២– គ្រប់គ្រងអោយបាននូវចំនួនពិតប្រាដ នៃមន្ត្រីរាជការដែលកំពុងមានសកម្មភាពជាក់ស្តែងក្នុងស្ថាប័នរដ្ឋនីមួយៗ ។

រាជរដ្ឋាភិបាល នឹងចេញសារាចរមួយពន្យល់អំពីរបៀប នៃកិច្ចប្រតិបត្តិការនេះ ។ សារាចរនោះនឹងរំលឹកផងដែរនូវករណីទទួលខុសត្រូវរបស់ជនដែលប្រព្រឹត្តខុសឆ្គងនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅកណ្ដាលតំបន់អភិវឌ្ឍន៍ ។ ការត្រៀមចូលជាសមាជិក នៃអង្គការ អាស៊ាននាពេលអនាគត ជាសក្ខីភាព នៃការប្ដេជ្ញារបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយប្រទេសឆ្ពោះទៅកាន់ ការរីកចំរើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ។ ហេតុនេះចាំបាច់ត្រូវមានរដ្ឋបាលមួយប្រកបដោយកិត សមស្រប ។

ដោយយោងតាមស្មារតីខាងលើនេះ រាជរដ្ឋាភិបាលសូមអំពាវនាវចំពោះប្រជាពលរដ្ឋ ជាពិសេស មន្ត្រីរាជការ ដើម្បីរួមសហការក្នុងការកសាងរដ្ឋបាលសាធារណៈមួយប្រកបដោយសមត្ថភាព ភាពស្អាតស្អំ និងអព្យាក្រឹតភាពដែលអាចធានាបានរាល់សកម្មភាព បំរើប្រជារាស្ត្រ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ០១ ឆ្នាំ ១៩៩៥

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ — ហ៊ុន សែន